មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# របាយការណ៍បូកសរុបការងារប្រចាំឆ្នាំ ២០២៣

| | |
|---|---|
| **ឈ្មោះស្ថាប័ន** | **មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")** |
| **គោលដៅ** | ចក្ខុវិស័យរបស់ ម.ស.ម.ក គឺចង់ឃើញប្រទេសកម្ពុជាមានសន្តិភាពដែលពលរដ្ឋគ្រប់រូបអាចអនុវត្តសិទ្ធិមនុស្សមូលដ្ឋានដែលខ្លួនមានពីកំណើត ទទួលបាននីតិរដ្ឋដោយគ្មាននិទណ្ឌភាព ទទួលបានការគោរពស្មើភាពគ្នាដោយគ្មានការរើសអើង ទទួលបានការពង្រឹងភាពអង់អាចក្លាហានដើម្បីចូលរួមយ៉ាងពេញលេញក្នុងដំណើរការលទ្ធិប្រជាធិបតេយ្យ ព្រមទាំងទទួលបានចំណែកនៃអត្ថប្រយោជន៍ពីការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពរបស់ប្រទេសកម្ពុជា។ |
| **រយៈពេល** | ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២៣ |

ក្នុងអំឡុងពេលពីខែមករា ដល់ខែធ្នូ ឆ្នាំ២០២៣ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក") បានអនុវត្តសកម្មភាពការងាររបស់ខ្លួនដូចមានរៀបរាប់ខាងក្រោម ៖

## ១. សកម្មភាពការងារសំខាន់ដែលសម្រេចបានក្នុងឆ្នាំ២០២៣

***ការចេញឯកសារផ្សព្វផ្សាយ***

នៅក្នុងឆ្នាំ២០២៣ នេះ ម.ស.ម.ក បានចេញឯកសារផ្សព្វផ្សាយសរុបចំនួន៨៦ ឯកសារដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្សក្នុងនោះរួមមានកំណត់ត្រាសង្ខេប របាយការណ៍ស្រាវជ្រាវ សលាកបត្រព័ត៌មាន ប័ណ្ណព័ត៌មាន ខិតប័ណ្ណព័ត៌មាន សេចក្តីថ្លែងការណ៍ លិខិតចំហ និងវីដេអូជាដើម។ ឯកសារទាំងនេះចេញផ្សាយក្នុងគោលបំណងអប់រំផ្សព្វផ្សាយ តស៊ូមតិ យុទ្ធនាការ ដើម្បីលើកកម្ពស់ការយល់ដឹងអំពីបញ្ហាសិទ្ធិមនុស្សរួមមានសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រការបង្ហាញទំនោរយេនឌ័រនិងលក្ខណៈភេទ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី សិទ្ធិជំនុំជម្រះដោយយុត្តិធម៌ និងសិទ្ធិជនជាតិដើមភាគតិចជាដើម។ ក្នុងចំណោមការចេញផ្សាយចំនួន៨៦ ឯកសារ មាន ៥ ឯកសារគឺជាវីដេអូដែលម.ស.ម.ក បានផលិតឡើងសម្រាប់ការអប់រំផ្សព្វផ្សាយ។ សាធារណជនអ្នកអាចទស្សនាវីដេអូទាំងនេះនៅលើបណ្តាញសង្គមយូធូបនិងទំព័រហ្វេសប៊ុក របស់ ម.ស.ម.ក។

## *ការឃ្លាំមើលនិងសង្កេតការណ៍សវនាការ*

ម.ស.ម.ក បានបន្តតាមដានអត្ថបទចេញផ្សាយតាមសារព័ត៌មាននានាក្នុងគោលបំណងទទួលបានព័ត៌មានទាន់ហេតុការណ៍ជុំវិញព្រឹត្តិការណ៍នានានិងបញ្ហាសំខាន់ៗមួយចំនួនដែលផ្តោតទៅលើសិទ្ធិសេរីភាពមូលដ្ឋាន សិទ្ធិដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា សិទ្ធិស្ត្រី និងស្ថានភាពសិទ្ធិមនុស្សដទៃទៀតនៅទូទាំងប្រទេស។ ជាសរុបក្នុងរយៈពេលនៃរបាយការណ៍នេះ ម.ស.ម.ក បានប្រមូលព័ត៌មានចំនួន៦៦៣ អត្ថបទដែលចេញផ្សាយតាមសារព័ត៌មាននានាពាក់ព័ន្ធនឹងសិទ្ធិសេរីភាពមូលដ្ឋាន សេរីភាពខាងការជួបប្រជុំ សេរីភាពខាងការបញ្ចេញមតិ សេរីភាពខាងសមាគម និងសិទ្ធិដីធ្លី ជាដើម។

ម្យ៉ាងទៀត ជាផ្នែកនៃគម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក្នុងឆ្នាំ២០២៣ ម.ស.ម.ក បានសង្កេតសវនាការក្នុងករណីព្រហ្មទណ្ឌចំនួន៧៦៥ ករណីនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ សាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង និងសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ និងករណីពាក់ព័ន្ធនឹងអំពើហិង្សាទាក់ទងនឹងយេនឌ័រចំនួន១០ ករណីនៅសាលាដំបូងខេត្តកំពង់ចាម និងខេត្តសៀមរាប។ លទ្ធផលនៃការសង្កេតសវនាការករណីព្រហ្មទណ្ឌនៅសាលាឧទ្ធរណ៍ ម.ស.ម.ក បាននាំយកលទ្ធផលដំបូងនៃការសង្កេតសវនាទៅជួបពិភាក្សាជាមួយសាលាឧទ្ធរណ៍ខេត្តត្បូងឃ្មុំ សាលាឧទ្ធរណ៍ខេត្តបាត់ដំបង និងសាលាឧទ្ធរណ៍ខេត្តព្រះសីហនុ ដើម្បីទទួលយកធាតុចូលនិងការអនុវត្តកាន់តែប្រសើរឡើងចំពោះសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

## *យុទ្ធនាការ*

- *ទិវានារីអន្តរជាតិ ខែមីនា ឆ្នាំ២០២៣*

ចាប់ពីថ្ងៃទី១៤ ខែកុម្ភៈ ដល់ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២៣ ម.ស.ម.ក បានរៀបចំកម្មវិធីអបអរសាទរទិវានារីអន្តរជាតិ។ យុទ្ធនាការនេះរៀបចំឡើងក្នុងគោលបំណងលើកកម្ពស់ការយល់ដឹងក្នុងចំណោមសាធារណៈជនអំពីការចូលរួមរបស់ស្ត្រីនៅក្នុងសង្គមស៊ីវិល និងបង្ហាញពីបញ្ហាប្រឈមដែលស្ត្រីចូលរួមនៅក្នុងសង្គមឬការចូលរួមជាសាធារណៈនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងយុទ្ធនាការ ម.ស.ម.ក បានរៀបចំសកម្មភាពជាច្រើនរួមមានទាំងការកៀរគរឲ្យសាធារណៈជនចូលរួមប្រកួតថតរូបទាក់ទងសិទ្ធិស្ត្រី ការចេញផ្សាយសេចក្តីថ្លែងការណ៍ ការជជែកផ្សាយផ្ទាល់កម្មវិធីវិទ្យុ ការចេញផ្សាយខិត្តប័ណ្ណព័ត៌មានស្តីពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងការរៀបចំព្រឹត្តិការណ៍ដើម្បីអបអរសាទរទិវានារីអន្តរជាតិ។

- *យុទ្ធនាការ១៦ ថ្ងៃដើម្បីបញ្ចប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងទិវាសិទ្ធិមនុស្សអន្តរជាតិ*

នៅខែវិច្ឆិកា និងខែធ្នូ ឆ្នាំ២០២៣ ម.ស.ម.ក បានរៀបចំទិវាអន្តរជាតិសំខាន់ៗរបស់អង្គការសហប្រជាជាតិ។ នៅថ្ងៃទី២៥ ខែវិច្ឆិកា គឺជាទិវាអន្តរជាតិដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី។ យុទ្ធនាការ១៦ ថ្ងៃនេះមានគោលបំណងផ្សព្វផ្សាយ និងលើកកម្ពស់ការយល់ដឹងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងសហគមន៍ និងដើម្បីស្នើ

ឲ្យរដ្ឋាភិបាលកម្ពុជាចាត់វិធានការជាបន្ទាន់និងច្បាស់លាស់ដើម្បីបញ្ចប់អំពើហិង្សាលើស្ត្រី និងលើកកម្ពស់សមភាពយេនឌ័រនៅកម្ពុជា។ ម.ស.ម.ក បានរៀបចំយុទ្ធនាការនេះចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា រហូតដល់ទិវាសិទ្ធិមនុស្សអន្តរជាតិនាថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៣ ដែលជាទិវាសំខាន់ដើម្បីប្រារព្ធខួបទី៧៥ នៃការប្រកាសប្រើប្រាស់សេចក្តីប្រកាសជាសាកលអំពីសិទ្ធិមនុស្ស ដែលជាឯកសារដ៏សំខាន់ពាក់ព័ន្ធនឹងក្របខណ្ឌសិទ្ធិមនុស្សអន្តរជាតិ និងជាសិទ្ធិមនុស្សមូលដ្ឋានរបស់បុគ្គលគ្រប់រូប។ យុទ្ធនាការរបស់ម.ស.ម.ក បានរៀបចំនូវសកម្មភាពជាច្រើនបន្តបន្ទាប់នៅលើបណ្តាញផ្សព្វផ្សាយសង្គម ដើម្បីទាក់ទាញឲ្យមានការចូលរួមពីសាធារណជនផងដែរ។ សកម្មភាពទាំងនោះរួមមានរួមមានទាំងការកៀរគឲ្យសាធារណៈជនចូលរួមបង្កើតសំណួរទាក់ទងនឹងអំពើហឹង្សាផ្អែកលើយេនឌ័រតាមអនឡាញ ការចេញផ្សាយបច្ចុប្បន្នភាពកាលប្បវត្តកូដកម្មរបស់បុគ្គលិកណាហ្គា ការចេញផ្សាយខិត្តប័ណ្ណព័ត៌មានស្តីពីវឌ្ឍនភាព នៃការអនុវត្តអនុសាសន៍របស់រដ្ឋាភិបាលទៅលើយន្តការនៃការត្រួតពិនិត្យជាសាកលតាមកាលកំណត់អំពីសិទ្ធិស្ត្រី ការផ្សាយជជែកផ្ទាល់កម្មវិធីវិទ្យុ និងការរៀបចំព្រឹត្តិការណ៍ផ្ទាល់ក្នុងឱកាសទិវា១៦ ថ្ងៃដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ និងទិវាសិទ្ធិមនុស្សអន្តរជាតិ និងការចេញផ្សាយបណ្ណព័ត៌មានអំពីព្រឹត្តិការណ៍សិទ្ធិមនុស្សសំខាន់នៅក្នុងឆ្នាំ២០២៣។

***<u>កម្មវិធីវិទ្យុ</u>***

នៅឆ្នាំ២០២៣ ម.ស.ម.ក បានផលិតកម្មវិធីផ្សាយផ្ទាល់កិច្ចពិភាក្សាតាមវិទ្យុចំនួន១៦៦ លើក ដោយផ្តោតលើប្រធានបទនានាតាមវិស័យនីមួយៗដូចមានដីធ្លី ធុរកិច្ចនិងសិទ្ធិមនុស្ស សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិអ្នកស្រឡាញ់ភេទដូចគ្នា និន្នាការភេទនិងអត្តសញ្ញាណយេនឌ័រ ការពិភាក្សាអំពីច្បាប់និងការវិភាគប្រចាំសប្តាហ៍។ ក្នុងកម្មវិធីពិភាក្សាទាំងនោះសុទ្ធតែមានការអញ្ជើញវាគ្មិនចម្រុះដែលមកពីអង្គការសង្គមស៊ីវិល គណៈមេធាវី និងរដ្ឋាភិបាលដើម្បីចូលរួមចែករំលែកនូវគំនិតយោបល់ក្នុងកិច្ចពិភាក្សា។ រាល់កម្មវិធីពិភាក្សាទាំងអស់ក៏មានផ្សព្វផ្សាយបន្តផ្ទាល់នៅលើគេហទំព័រហ្វេសប៊ុករបស់ម.ស.ម.ក ផងដែរ ដែលទទួលបានព័ត៌មានចំនួន ៩ ១០៥ ៨៦៦, ទទួលបានការចុច Like ចំនួន ៣៧៥៥៤ ចែករំលែកបន្តចំនួន ៤៣៦៥ ចូលទស្សនាចំនួន ២៥៨៨ ៥៥៩ និងផ្តល់មតិយោបល់ចំនួន ២៥៥២។

## ២. ការប្រឈមនិងបទពិសោធន៍

ក្នុងឆ្នាំ២០២៣ ម.ស.ម.ក បានអនុវត្តការងារសកម្មភាពរបស់ខ្លួនទៅតាមផែនការគ្រោងទុក ទោះបីជាសកម្មភាពមួយចំនួនមានការយឺតយ៉ាវក៏ដោយ។

## ៣. ការបញ្ជ្រាបយេនឌ័រ

ម.ស.ម.ក នៅតែអនុវត្តសកម្មភាពការងាររបស់ខ្លួនដើម្បីធានាយ៉ាងណាឲ្យមានសមភាពយេនឌ័រ ជាពិសេសការចូលរួមរបស់ស្ត្រី។ នៅគ្រប់ពេលទាំងអស់ ម.ស.ម.ក តែងតែលើកឡើងពីស្ថានភាពផ្លូវច្បាប់ស្មើភាពគ្នារវាងបុរស ស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាទាក់ទងនឹងសិទ្ធិមនុស្ស។

លើសពីនោះ ម.ស.ម.ក បានរៀបចំព្រឹត្តិការណ៍សំខាន់មួយចំនួនដើម្បីលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅក្នុងឱកាសនៃទិវានារីអន្តរជាតិ ០៨ មីនា ឆ្នាំ២០២៣ យុទ្ធនាការ ១៦ ថ្ងៃដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងនៅតែបន្តផ្តល់ជំនួយផ្នែកច្បាប់ មនុស្សធម៌ និងផ្លូវចិត្តតាមលទ្ធភាពដែលអាចធ្វើទៅបានដល់អ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងអ្នកស្រឡាញ់ភេទដូចគ្នាដែលបានប្រឈមនឹងអំពើហិង្សា ការយាយី និងការគំរាមកំហែងដោយសារការងាររបស់ពួកគេ៕

## ៤. ឧបសម្ពន្ធ

ឯកសារចេញផ្សាយសំខាន់ៗរបស់ ម.ស.ម.ក រួមមាន ៖

របាយការណ៍ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតសវនាការនៅសាលាឧទ្ធរណ៍ភ្នំពេញ បាត់ដំបង ត្បូងឃ្មុំ និងព្រះសីហនុ (ថ្ងៃទី១ ខែមករា ដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២)

--- ចប់ ---